# គោលនយោបាយចល័តភាពគឺជាគន្លឹះសម្រាប់និរន្តរភាពនៃបរិស្ថាន



ការប្រើប្រាស់ថយន្តគឺជាកត្តាចម្បង ដែលបង្កឱ្យមានការប៉ះពាល់ដល់បរិស្ថានបៃតង។ ការយល់ដឹងរវាងការតភ្ជាប់គោលនយោបាយចល័តភាព និងការរិចរិលនៃបរិស្ថានធម្មជាតិ គឺជាកត្តាចាំបាច់ ព្រោះវាជាគន្លឹះក្នុងការទប់ស្កាត់ការបាត់បង់បរិស្ថានធម្មជាតិបន្ថែមទៀត។ អត្ថបទនេះ បង្ហាញពីមូលហេតុនៃការបាត់បង់បរិស្ថានធម្មជាតិពីទស្សនៈនៃការពង្រីកទីក្រុង និងដំណោះស្រាយក្នុងការបង្រួមទីក្រុងគឺជាផ្លូវតម្រង់ទិសក្នុងការអភិវឌ្ឍ។

ការពង្រីកទីក្រុង គឺជាកាលៈទេសៈដែលមិនអាចជៀសវាងបាននៅពេលដែលទីក្រុងកាន់តែរីកចម្រើន។ សម្ពាធសេដ្ឋកិច្ច និងការអភិវឌ្ឍបានកែប្រែអតីតដីស្រែចំការ ដីលិចទឹក និងបឹងទៅជាអគារ ផ្លូវ និង ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

ទីក្រុងភ្នំពេញតែងតែត្រូវបានពង្រីកទៅតាមនិន្នាការគ្រីនហ្វៀល (Greenfield) មានន័យថាការបំប្លែងបរិស្ថានធម្មជាតិដូចជា ផ្ទៃទឹក ដីលិចទឹក និងទេសភាពជនបទ ដើម្បីបង្កើតសង្កាត់ថ្មី។ ក្នុងប្រវត្តិសាស្ត្រ ទីតាំងដូចជាវត្តកោះ ពហុកីឡដ្ឋានជាតិអូឡាំពិក និងសួនច្បារស្ពាននាគ សុទ្ធតែជាកន្លែងមានទឹកដែលត្រូវបានលប់។ ដូចគ្នានេះដែរ ឈ្មោះនៃទីតាំងដែលសំដៅទៅទឹក ឧទាហរណ៍ បឹងកេងកង ទឹកថ្លា បឹងកក់ ស្រះចក និងបឹងត្របែកជាដើមក៏បង្ហាញឱ្យឃើញថាទីតាំងទាំងនោះធ្លាប់ជាបឹង និងផ្លូវទឹកផងដែរ។

ទោះជាយ៉ាងណាក៏ដោយ កំណើននៃនគរូបនីយកម្មនាពេលបច្ចុប្បន្នបានបណ្ដាលឱ្យមានវិបត្តិ។ ការរីកដុះដាលនៃទីក្រុងបង្កើនភាពមមាញឹក និងបញ្ហាដូចជា ការបណ្ដេញចេញ ការបាត់បង់ការងារ ការពឹងផ្អែកលើរថយន្តឯកជន និងការរិចរិលបរិស្ថាន។ ផលប៉ះពាល់អវិជ្ជមានទាំងនេះ មិនត្រឹមតែកើតឡើងចំពោះអ្នករស់នៅជិតតំបន់អភិវឌ្ឍប៉ុណ្ណោះទេ ប៉ុន្តែក៏ប៉ះពាល់ដល់ប្រជាពលរដ្ឋទូទៅក្នុងរាជធានីភ្នំពេញផងដែរ។

កន្លងមកការសិក្សា ការធ្វើអធិប្បាយ និងការផ្ដល់អនុសាសន៍នានា ហាក់បីដូចជាការនិយាយអំពីរោគសញ្ញានៃបញ្ហាតែប៉ុននោះ ខណៈពេលដែលអំពើពុករលួយ និងគិតតែរឿងប្រាក់ចំនេញរបស់វិនិយោគទុន ត្រូវបានគេលើកឡើងជាញឹកញាប់ថាជាកត្តាចម្បង ឬជាដើមហេតុដែលនាំឱ្យមានការរីករាលដាលទីក្រុងដោយខ្វះការគ្រប់គ្រង។ ដើម្បីរកដំណោះស្រាយដែលមានប្រសិទ្ធភាព ការវិភាគ និងការផ្ដល់អនុសាសន៍គួរឈ្វេងយល់កត្តាចម្បង ដែលជំរុញឱ្យទីក្រុងរីករាលដាលដោយគ្មានផែនការច្បាស់លាស់ ដូចជា កត្តាការប្រើប្រាស់យានយន្តឯកជន និងការរៀបចំទីក្រុងផ្ដោតទៅលើរថយន្តសាធារណៈ។

## សម្ពាធសេដ្ឋកិច្ច

ស្របពេលប្រទេសកម្ពុជាកំពុងរីកចម្រើនតម្រូវការសម្រាប់លំនៅឋាន កន្លែងពាណិជ្ជកម្ម និងកន្លែងបម្រើការងារសេវាកម្មកើនឡើងយ៉ាងខ្លាំង ជំរុញឱ្យមាននគរូបនីយកម្ម។ តម្រូវការនេះ ត្រូវបានបំពេញទាំងស្រុងដោយវិស័យឯកជន ដែលអភិវឌ្ឍនិងកែប្រែទេសភាពជនបទទៅជាតំបន់ទីក្រុងថ្មី ពោរពេញទៅដោយផ្ទះ អគារពាណិជ្ជកម្ម និងបរិក្ខារផ្សេងៗទៀត។ នៅក្នុងទីផ្សារសេរី ដែលតែងតែផ្ដោតលើប្រាក់ចំណេញតម្លៃអចលនៈទ្រព្យបានកើនឡើងខ្ពស់លើសលប់ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ដោយមិនមានការគ្រប់គ្រងឱ្យបានគ្រប់ជ្រុងជ្រោយ។ ជាការឆ្លើយតប ក្រុមហ៊ុនអភិវឌ្ឍបានជ្រើសរើសទីតាំងដែលនៅកាន់តែឆ្ងាយពីកណ្ដាលទីក្រុងភ្នំពេញ។ គម្រោងលំនៅឋានល្បីៗមួយចំនួន មានទីតាំងនៅតាមបណ្ដាខណ្ឌជាយក្រុងនានា ដូចជាខណ្ឌកំបូល ខណ្ឌដង្កោ និងខណ្ឌពោធិ៍សែនជ័យ ហើយស្ថិតនៅចម្ងាយជាង១៧គីឡូម៉ែត្រទៅ២១គីឡូម៉ែត្រ ពីកណ្ដាលទីក្រុងភ្នំពេញ។ ជាលទ្ធផល



គម្រោងលំនៅឋានភាគច្រើនមានចម្ងាយឆ្ងាយពីកន្លែងធ្វើការ សាលារៀន មណ្ឌលសុខភាព សេវាសាធារណៈ និងកន្លែងលំហែកាយ ដែលនាំឱ្យមានការធ្វើដំណើរប្រចាំថ្ងៃឆ្ងាយខ្លាំង។

ភាពរីកដុះដាលនៃទីក្រុងបានបង្ករឱ្យមានការថយចុះនៃបរិស្ថានធម្មជាតិកាន់តែខ្លាំងទៅៗ។ ឧទាហរណ៍ ជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍ទីក្រុងរបស់រាជរដ្ឋាភិបាលគ្រោងនឹងប្រគល់ដីព្រៃការពារនៅភ្នំតាម៉ៅក្នុងឆ្នាំ២០២២ ដែលមានចម្ងាយ ៤២ គីឡូម៉ែត្រ និងស្ថិតនៅភាគខាងត្បូងរាជធានីភ្នំពេញ។ ជាងពាក់កណ្ដាលនៃព្រៃភ្នំតាម៉ៅត្រូវបានធ្វើអនុប្រយោគ និងប្រគល់ឱ្យឧកញ៉ា ដែលធ្វើឱ្យមានការថ្កោលទោសយ៉ាងទូលំទូលាយពីសកម្មជនបរិស្ថាន និងសាធារណជនទូទៅ។ សង្គមស៊ីវិលបានដាក់សម្ពាធលើនាយករដ្ឋមន្ត្រីកម្ពុជាឱ្យបញ្ឈប់គម្រោងនេះ។ ជាអកុសល មួយសប្ដាហ៍មុនការអន្តរាគមន៍ អ្នកអភិវឌ្ឍបានឈូសឆាយដី ៥០០-៦០០ ហិកតារួចទៅហើយ។ សព្វថ្ងៃនេះ ព្រៃនៅភ្នំតាម៉ៅបានជួបជោគវាសនា ដូចគ្នានឹងបឹងជាច្រើនក្នុងរាជធានីភ្នំពេញដែរ ដែលនាំឱ្យសមាជិកសង្គមស៊ីវិលសម្ដែងការព្រួយបារម្ភកាន់តែខ្លាំងឡើងអំពីអនាគតនៃតំបន់ការពារធម្មជាតិ និងតំបន់ការពារជុំវិញទីក្រុង។

**តើកត្តាគោលនយោបាយរៀបចំទីក្រុងអ្វីខ្លះ ដែលជំរុញឱ្យមានការអភិវឌ្ឍន៍បែបរីករាលដាល?**

## ទីក្រុងផ្តោតលើរថយន្ត

គោលនយោបាយចល័តភាពទីក្រុង គឺជាកត្តាសំខាន់មួយក្នុងការតម្រង់ទិសដៅនគរូបនីយកម្ម។ ការពង្រីកទីក្រុងមួយដែលនាំឱ្យមានការបំផ្លាញធម្មជាតិ និងការបណ្តេញប្រជាជនចេញពីទីលំនៅ ឬការពង្រីកទីក្រុងដោយមានការថែរក្សាបរិស្ថានធម្មជាតិ និងកាត់បន្ថយផលប៉ះពាល់សង្គម គឺអាស្រ័យលើគោលនយោបាយចល័តភាពទីក្រុង។ ក្នុងករណីប្រជាជននៅទីក្រុងភ្នំពេញភាគច្រើនបានជ្រើសរើសយានជំនិះឯកជនជាមធ្យោបាយធ្វើដំណើរចម្បង។ ប្រាកដណាស់ បុគ្គលដែលមានលទ្ធភាពប្រើប្រាស់យានជំនិះផ្ទាល់ខ្លួន ដូចជាឡានទំនើបជាដើម អាចធ្វើដំណើរឆ្ងាយប្រចាំថ្ងៃបាន។ ប៉ុន្តែភាពងាយស្រួលនេះ បានជំរុញការពង្រីកទីក្រុងឱ្យកាន់តែឆ្ងាយទៅ ហួសផុតពីដែនកំណត់ចូលទៅដល់បរិស្ថានធម្មជាតិ។

ទីក្រុងដែលពឹងផ្អែកទាំងស្រុងលើយានជំនិះឯកជន គឺជាក្រុងដែលបង្កើតឡើងសម្រាប់យានយន្តឯកជន ដោយមិនបានលើកតម្កើងមធ្យោបាយធ្វើដំណើរផ្សេងទៀត។ ទីក្រុងបែបនេះមានដង់ស៊ីតេទាប (មានដង់ស៊ីតេប្រជាជនតិចជាង ១៥ ០០០ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ) សំណង់មិនមានការប្រើប្រាស់ចម្រុះ ការដឹកជញ្ជូនសាធារណៈមិនគ្រប់គ្រាន់ និងមានលក្ខណៈពិបាកសម្រាប់អ្នកធ្វើដំណើរថ្មើរជើងដែលធ្វើឱ្យពួកគេពឹងផ្អែកតែលើរថយន្ត។

នគរូបនីយកម្មបែបដង់ស៊ីតេទាប គឺជាការលូតលាស់នៃទីក្រុង ដែលទីតាំងនីមួយៗមានសភាពឆ្ងាយដាច់ស្រយាលពីគ្នា។ ជាឧទាហរណ៍ សាលារៀន ហាងលក់គ្រឿងទេស ការិយាល័យ ភោជនីយដ្ឋាន និងសួនច្បារនៅឆ្ងាយដាច់ពីគ្នា ដែលនាំឱ្យកាន់តែពិបាកធ្វើដំណើរទៅកាន់ទីតាំងទាំងនោះ។

បណ្តាញផ្លូវដែលស្មុគស្មាញ និងកង្វះផែនការច្បាស់លាស់ធ្វើឱ្យតំបន់នីមួយៗមានលក្ខណៈផ្តាច់ចេញពីគ្នា ដែលបណ្តាលឱ្យការធ្វើដំណើរមានភាពលំបាក។ សូម្បីតែការធ្វើដំណើរចម្ងាយជិតក៏មិនអាចប្រើមធ្យោបាយថ្មើរជើងបាននោះទេ ដោយសារកត្តា រួមផ្សំដូចជា ការបំពានចិញ្ចើមថ្នល់ដោយយានយន្ត និងអាជីវកម្មតាមដងផ្លូវ។ កត្តាខាងលើទាំងអស់នេះបានធ្វើឱ្យជម្រើសដឹកជញ្ជូនសាធារណៈគ្មានប្រសិទ្ធភាពទាំងស្រុង ដែលនេះជាមូលហេតុនាំឱ្យមានការពឹងផ្អែកទៅលើយានយន្តឯកជនកាន់តែខ្លាំងលើសលប់។

ការសិក្សានៅទីក្រុងឆាងឈុន (Changchun) នៃប្រទេសចិនបានបង្ហាញឱ្យឃើញថា ការសម្រេចចិត្តរបស់បុគ្គលក្នុងការប្រើប្រាស់រថយន្តផ្ទាល់ខ្លួនជាមធ្យោបាយធ្វើដំណើរចម្បង ផ្អែកលើលក្ខណៈសម្បត្តិនៃទីក្រុងក្នុងប្រទេសរបស់ពួកគេ។ កត្តារួមចំណែកនានាដូចជា ដង់ស៊ីតេប្រជាជនក្នុងទីក្រុង ប្លុក ឬតំបន់នៃទីក្រុងដែលមានការប្រើប្រាស់ចម្រុះ និងចម្ងាយទៅកាន់កណ្តាលទីក្រុង សុទ្ធតែជាកត្តារួមចំណែកនាំឱ្យមានការសម្រេចចិត្តក្នុងការជ្រើសរើសមធ្យោបាយធ្វើដំណើរមួយដែលសាកសម។

ដូច្នេះ ករណីរាជធានីភ្នំពេញ ដែលពឹងផ្អែកលើរថយន្តបានជំរុញអ្នករស់នៅឱ្យចាំបាច់ត្រូវប្រើប្រាស់យានជំនិះឯកជនសម្រាប់ធ្វើដំណើរប្រចាំថ្ងៃ។ កត្តានេះក៏ជំរុញធ្វើឱ្យទីក្រុងកាន់តែមានការរីកដុះដាលកាន់តែធំទៅទីតាំងអតីតដីលិចទឹក បឹង និងដីស្រែជាដើម ដែលបំផ្លាញបរិស្ថានធម្មជាតិនៅជុំវិញរាជធានីភ្នំពេញ។ នាពេលអនាគត ប្រសិនបើរាជធានីភ្នំពេញមិនអាចផ្លាស់ប្តូរចេញពីគោលនយោបាយចល័តភាពទីក្រុង ដែលពឹងផ្អែកលើយានយន្តឯកជននោះទេ គឺនឹងនាំឱ្យមានការបំផ្លិចបំផ្លាញ រួមជាមួយនឹងការខូចខាតបរិស្ថាន និងផលប៉ះពាល់ដល់សុខភាពប្រជាជនទីក្រុងភ្នំពេញទាំងមូល។

## ការបង្រួមទីក្រុង



កំណើននគរូបនីយកម្ម គឺផ្សារភ្ជាប់ជាមួយនឹងកំណើនសេដ្ឋកិច្ច និងវិបុលភាពនៃប្រទេស។ ដូច្នេះហើយ ការរីកលូតលាស់នៃទីក្រុងគឺត្រូវតែកើតមាន ហើយនគរូបនីយកម្មក៏អាចមានលក្ខណៈ ដែលមិនប៉ះពាល់អវិជ្ជមានដល់ជីវភាពប្រជាជន និងបរិស្ថានបានដែរ។ ក្នុងកិច្ចពិភាក្សារកដំណោះស្រាយសម្រាប់ការពង្រឹងការអភិរក្សតំបន់ធម្មជាតិ ទោះបីមានប្រយោជន៍ក្តី វាអាចព្យាបាលតែរោគសញ្ញានៃជំងឺតែប៉ុណ្ណោះ ប៉ុន្តែមិនអាចរកដំណោះស្រាយមូលហេតុដើមនោះទេ។ ដូច្នេះ ដើម្បីអភិរក្សតំបន់ធម្មជាតិនៅជិតទីក្រុង និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានផ្សេងៗក្នុងសង្គម (ការបណ្តេញចេញពីលំនៅឋាន ការបាត់បង់ការងារ) ដែលបណ្តាលមកពីការអភិវឌ្ឍ វាជាការចាំបាច់ដែលបញ្ហានេះត្រូវដោះស្រាយតាមរយៈគោលនយោបាយនគររូបនីយកម្ម។ ជម្រើសមួយដែលល្អប្រសើរ គឺជាការរៀបចំទីក្រុងដែលមានលក្ខណៈបង្រួបបង្រួម។ គោលបំណងនៃវិធីសាស្ត្របង្រួបបង្រួម គឺការបង្កើតទីក្រុងមួយដែលមានផ្ទៃដីតូចជាជាងការរីករាលដាល និងផ្ទុយពីគំរូបច្ចុប្បន្ន។ ករណីសិក្សាមួយបានប្រៀបធៀបរវាងទីក្រុងអាត្លង់តាក្នុងសហរដ្ឋអាមេរិក និងទីក្រុងបាសេឡូណាក្នុងអេស្ប៉ាញ បានបង្ហាញយ៉ាងច្បាស់ពីភាពខុសគ្នារវាងទីក្រុងដែលលាតធំ និងទីក្រុងដែលផ្តោតលើការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព។

អាត្លង់តា គឺជាទីក្រុងដែលពឹងផ្អែកយ៉ាងខ្លាំងលើរថយន្ត ហើយគ្របដណ្តប់លើផ្ទៃដី៧,៦៩២ គីឡូម៉ែត្រការ៉េ ជាមួយនឹងប្រជាជនចំនួន ៥.៣លាននាក់។ ខណៈពេលដែល បាសេឡូណាមានចំនួនប្រជាជនស្រដៀងគ្នា ប៉ុន្តែវាគ្របដណ្តប់តំបន់មួយត្រឹមតែ ១/១២ នៃទំហំរបស់អាត្លង់តា។

អាត្លង់តាជាតំបន់ដែលមានផ្លូវធំៗ និងចំណតរថយន្តច្រើន ចំណែកឯបាសេឡូណាវិញ មានផ្លូវថ្មើរជើង សួនសាធារណៈ ហាង និងលំនៅឋាន ដែលទាំងអស់នេះស្ថិតក្នុងប្លុកទីក្រុងតែមួយ។ អាត្លង់តាជួបប្រទះនឹងបញ្ហា ដូចជាការស្ទះចរាចរណ៍ និងភាពចល័តក្នុងទីក្រុងមិនសូវល្អក៏ដូចជាការបំភាយកាបូនច្រើនហួសហេតុ ខណៈពេលដែលបាសេឡូណារៀបចំឱ្យប្រជាពលរដ្ឋរបស់ខ្លួនរស់នៅជុំវិញប្រព័ន្ធធ្វើដំណើរសាធារណៈដ៏មានប្រសិទ្ធភាព និងបង្កើតជាតំបន់ដែលអាចដើរបាន និងអាចជិះកង់បាន។

អាត្លង់តាត្រូវស៊ូទ្រាំនឹងកំដៅក្នុងទីក្រុងដែលស្ទើរតែមិនអាចទទួលយកបាន ដោយសារផ្ទៃបេតុងនៃចំណត់រថយន្ត និងផ្លូវកៅស៊ូធំៗ ផ្ទុយទៅវិញ បាសេឡូណាមានភាពត្រជាក់ដោយសារមានដើមឈើឧទ្យាន និងសួនតាមមាត់ទឹកជាច្រើន។

លើសពីនេះ បាសេឡូណាមិនមែនជាព្រៃនៃអគារខ្ពស់ៗនោះទេ។ អគារភាគច្រើនមានកម្ពស់ត្រឹមតែ៥ទៅ៦ជាន់ប៉ុណ្ណោះ ប៉ុន្តែអាចរក្សាបាននូវលំនៅឋាន ហាង សេវាកម្មសំខាន់ៗ និងសកម្មភាពជាច្រើន។ ម្យ៉ាងទៀត ប្លុកនីមួយៗមានលក្ខណៈងាយស្រួលក្នុងការធ្វើដំណើរថ្មើរជើង។

គំរូនៃទីក្រុងបាសេឡូណាបង្ហាញឱ្យឃើញថា ការអភិវឌ្ឍបែបបង្រួមមិនចាំបាច់មានភាពចង្អៀត ឬអាគារខ្ពស់ស្កឹមស្កៃនោះទេដើម្បីទទួលបានជោគជ័យ។ ជាការពិត ដង់ស៊ីតេសមរម្យគឺជាគុណសម្បត្តិមួយ ព្រោះលំនៅឋាន ស្ថាប័នអប់រំ ឱកាសការងារ សេវាកម្មជាដើម កាន់តែខិតជិតគ្នា កាន់តែធ្វើឱ្យការដឹកជញ្ជូនសាធារណៈមានភាពប្រសើរ និងការ

ធ្វើដំណើរកាន់តែមានប្រសិទ្ធភាព។ ចំណុចសំខាន់បំផុត គឺទីក្រុងដែលបង្រួមផ្ទៃក្រឡាក៏ជួយថែរក្សាប្រព័ន្ធអេកូឡូស៊ីជុំវិញផងដែរ។

## មេរៀនពីទីក្រុងបាសេឡូណាជាគំរូអភិវឌ្ឍន៍ដ៏ល្អមួយសម្រាប់រាជធានីភ្នំពេញ

### ទីក្រុងបង្រួមរក្សាជម្រកធម្មជាតិ

អ្នកប្រហែលជាមានចម្ងល់ថា បើមានការកំណត់អាទិភាពវិធីសាស្ត្របង្រួមអាចនាំឱ្យមានការសាងសង់អគារខ្ពស់ៗឬទេ? គឺមិនមែនទេ ទីក្រុងបាសេឡូណាបង្ហាញរួចហើយការកំណត់ទំហំទីក្រុងឱ្យនៅតូចសមរម្យមិនតែងតែនាំទៅដល់ការសាងសង់អគារខ្ពស់ៗនោះទេ។



ភាពបង្រួមមានន័យថា កំណើននៃការប្រើប្រាស់លំហនៅក្នុងតំបន់ទីក្រុង។ គ្រប់អគារគួរតែជាអគារដែលប្រើប្រាស់ចម្រុះ និងពហុគោលបំណងដែលរួមមានលំនៅឋាន ភោជនីយដ្ឋាន ហាងលក់ទំនិញ។ល។ ការធ្វើតាមគំរូបែបបង្រួមមានន័យថាអ្នកអភិវឌ្ឍនឹងជៀសវាងសាងសង់កន្លែង ដែលមានការប្រើប្រាស់តែមួយ ដូចជាយានដ្ឋាន និងទីលានវាយកូនហ្គោលជាដើម។ ផ្ទុយទៅវិញ ទីធ្លាសាធារណៈ ផ្លាហ្សានិងសួនឧទ្យាន ដែលបម្រើគ្រប់លក្ខណៈនៃមុខងារសង្គមវប្បធម៌លំហែកាយ និងសេដ្ឋកិច្ចគួរតែត្រូវបានផ្តល់អាទិភាពជាធំ។

ដូចគ្នានេះដែរ ការដឹកជញ្ជូនក៏ត្រូវតែបង្រួបបង្រួមដូចគ្នាដែរ។ ការសាងសង់ផ្លូវធំៗ ចំណតយានយន្ត និងយានដ្ឋានរាប់មិនអស់គួរតែត្រូវបានជៀសវាង។ ជំនួសមកវិញការធ្វើដំណើរគួរតែផ្លាស់ប្តូរមកមានការប្រើប្រាស់ឡានក្រុងដែលផ្ទុកអ្នកធ្វើដំណើរបានច្រើនជាង ប៉ុន្តែមានតម្លៃថោកក្នុងការធ្វើដំណើរ និងមាននិរន្តរភាពក្នុងការថែរក្សា ផ្លូវជិះកង់ និងចិញ្ចើមថ្មើរជើង។ ជាងនេះទៅទៀត ការសាងសង់ប្លុកទីក្រុងឱ្យមានភាពងាយស្រួលក្នុងការថ្មើរជើង ធ្វើឱ្យការធ្វើដំណើរសកម្ម និងការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ ក្លាយទៅជាជម្រើសដ៏ងាយស្រួល និងទាក់ទាញសម្រាប់អ្នករស់នៅ។

## សេចក្តីសន្និដ្ឋាន

ដូច្នេះវិធីសាស្ត្របង្រួមនេះ គ្រាន់តែអំពាវនាវឱ្យយើងប្រើប្រាស់លំហដែលយើងមានរួចមកហើយឱ្យមានភាពចម្រុះ និងអស់ពីលទ្ធភាព ដែលកាត់បន្ថយតម្រូវការក្នុងការសាងសង់អគារខ្ពស់ ឬសាងសង់បែបពង្រីករាលដាល។ ជាចំណុចបញ្ចប់ការផ្លាស់ប្តូរគោលនយោបាយចល័តភាព ចេញពីការពឹងផ្អែកលើយានយន្តឯកជន នាំឱ្យទីក្រុងមានលក្ខណៈបង្រួម មិនត្រឹមតែនាំឱ្យទីក្រុងមានភាពងាយស្រួលក្នុងការរស់ប៉ុណ្ណោះទេ ប៉ុន្តែក៏បានជួយសម្របសម្រួល ការថែរក្សាបរិស្ថានធម្មជាតិ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានសង្គមផងដែរ។

**អត្ថបទសិក្សាស្រាវជ្រាវខ្លីខាងលើនេះ ឆ្លុះបញ្ចាំងពីជាទស្សនៈរបស់អ្នក**
**ស្រាវជ្រាវវ័យក្មេងលើជ្រុងមួយនៃការអភិវឌ្ឍន៍ក្រោមប្រធានបទ៖**
**“ គោលនយោបាយចល័តភាព**
**គឺជាគន្លឹះសម្រាប់និរន្តភាពនៃបរិស្ថាន”**

**បញ្ជាក់អត្ថបទនេះ មិនបានសិក្សាស្រាវជ្រាវស៊ីជម្រៅ និងឆ្លុះបញ្ចាំងអំពី*
*ទស្សនៈរបស់អង្គការសមាគមផាងត្នោត (ស.ផ.ត)។*